«សែន សុខណានីន?»

អាសាន់អានឈ្មោះគេនោះឮៗ ធ្វើឱ្យខ្ញុំសឹងតែលើកដៃទះត្បូកក្បាលវា ហើយសួរថា «អ្នែងមិនដាក់មេក្រូស្រែកហ្មងទៅ?» តែខ្ញុំគាំងអណ្ដាតវិញ ព្រោះតែដើមឈើមួយនៅពីក្រោយរូបថតរបស់គេ។ រូបថតស្រីស្អាតម្នាក់នោះ។

ដើមឈើធំខ្ពស់មានខ្មែងបែកជាពីរច្បាស់ទែងរាងរៅដូចចម្ពាមសម្រាប់បាញ់សត្វ។ បេះដូងខ្ញុំលោតភ្លឹប នឹកទៅដល់សម្ដីតាម្ចាស់ដើមបំពេញរាជ្យកាលពីជាងមួយខែមុនដែលគាត់ជម្រាបពុកខ្ញុំ ដើមឈើដែលមានរូបរាងបែបនេះមិនអាចរក្សាទុកបានទេ។

ខ្ញុំរវើ្មកមកសម្លឹងទឹកមុខដ៏ស្រងូតរបស់ម្ចាស់ហ្វេសប៊ុកដ៏ស្រស់ស្អាត...

នាងមានទឹកមុខក្រៀមក្រំបែបនេះតាំងពីពេលដែលខ្ញុំបានជួបនៅកន្លែងផ្ញើម៉ូតូ? នាងដឹងទេថា ដើមឈើខាងក្រោយរូបរបស់នាង ជាដើមឈើអពមង្គល?

ខ្ញុំក្រោករឹងចោលអាសាន់។

ថ្នាក់រៀនរបស់ណានីន នៅអាគារមួយផ្សេងចម្ងាយប្រមាណ ១០០ ម៉ែត្រពីកន្លែងខ្ញុំអង្គុយ។

មកដល់ជណ្ដើរ ខ្ញុំដើរឡើងយឺតៗទៅជាន់ទីបីខាងលើ ព្រោះខ្ញុំហត់ណាស់ តែចិត្តមួយ ខ្ញុំចង់ប្រាប់នាងឱ្យដឹងពីអ្វីដែលខ្ញុំបានដឹងទាក់ទងនឹងដើមឈើរូបចម្ពាមនៅពីក្រោយខ្នងនាងក្នុងរូបថត Profile ហ្វេសប៊ុក។

ស្នូរជើងនិស្សិតជាច្រើនដើរមកដល់ ខ្ញុំក៏អត់ធ្មត់ឈប់ដកដង្ហើមដង្ហក់ ហើយឡើងមួយៗសំដៅគោលដៅ។ ស្រីៗបួននាក់ដើររាយគ្នាជាជួរមកដល់។ ពួកគេសម្លឹងខ្ញុំដូចជាចម្លែក ហើយក៏បង្ហួសទៅមុខ។

វត្តមានខ្ញុំរមែងអាចធ្វើឱ្យគេឆ្ងល់ ព្រោះខ្ញុំមិនមែនរៀននៅទីនេះ ដូច្នេះខ្ញុំមិនចម្លែកអ្វីនឹងអាការៈរបស់ពួកគេទេ គោលដៅរបស់ខ្ញុំគឺរកណានីនឱ្យឃើញ។

ដូចរាល់ដងដែលខ្ញុំតាមមើលនាង នាងគ្មានមិត្ត ហើយចូលចិត្តអង្គុយឆ្ងាយពីគេឯងអានសៀវភៅយ៉ាងស្រងូតស្រងាត់។

ខ្ញុំឈរសម្លឹងគេពីក្រោយទាំងមិនដាច់ចិត្តចូលទៅរាក់ទាក់សោះ ប៉ុន្តែរាងដើមឈើរាងចម្ពាមនោះចាក់ដោតចិត្តខ្ញុំបំផុតហើយ។

ខ្ញុំគិតថាលើកនេះគ្មានអីត្រូវលីបលទេ ព្រោះពិតជាមានការមែនដែលចង់ប្រាប់នាងជាបន្ទាន់ គ្រាន់តែមិនដឹងថាគួរចាប់ផ្តើមពីណាទៅណា? ខ្ញុំឱនសម្លឹងការតុបតែងរបស់ខ្លួនឯងមួយគ្រួសមុនពេលសម្រេចចិត្តចុងក្រោយថាចូលទៅនិយាយនឹងនាង។

មិនទាន់ងើបមុខមកវិញផង…

«តាមដានខ្ញុំយូរហើយ តាមមិនចេះឆ្អែតទេ?»

ខ្ញុំភាំង ព្រោះគេងាកមកនិយាយត្រមុំតត្រមុំយបែបនេះដាក់ខ្ញុំ។ តើឱ្យខ្ញុំរកពាក្យអ្វីមកឆ្លើយនឹងគេបានភ្លាមៗក្នុងស្ថានភាពរបៀបនេះ? គេមិនត្រឹមមានទឹកមុខសោះកក្រោះទេ ថែមទាំងមានសំឡេងស្ងួតគ្មានមនោសញ្ចេតនាទៀត ទើបនឹងមកពីមានរឿងជាមួយអ្នកណាមក ក៏មិនដឹង? ខ្ញុំនេះមកមិនត្រូវពេលឬអ្វី?

«អត់ការងារធ្វើមែន?»

នាងសម្លឹងខ្ញុំថ្មៃ ពេលនិយាយប្រយោគទីពីរនេះ។ ខ្ញុំតាំងចិត្តនិយាយរកខុសត្រូវ ទោះបីជាទទួលស្គាល់ថា កន្លងមកធ្លាប់តាមដាននាងមែន តែនាងមិនសមមានសម្តីសំដៅរបៀបនេះមករកអ្នកដែលចូលចិត្តខ្លួនទេ។

«ណានីន! ខ្ញុំគ្រាន់តែចង់មកនិយាយប្រាប់ពីដើមឈើរូបចម្លាមនោះ!»

នាងចងចិញ្ចើមហាក់មិនយល់អ្វីទាំងអស់ តួនាទីរបស់ខ្ញុំគឺខ្ញុំត្រូវខំនិយាយពន្យល់បន្ថែមយ៉ាងណាក៏ដោយ ឱ្យតែនាងព្រមជឿ ហើយទុកឱកាសឱ្យខ្ញុំពន្យល់៖

«គឺ Profile ហ្វេសប៊ុកដែលមានណានីនឯងថតហ្នឹង ថតនៅឯណា នៅផ្ទះមែនអត់?»

នាងក្រញូវសម្លក់ខ្ញុំមួយ មុនពេលដើរចេញពីមុខខ្ញុំ ដើរចូលទៅក្នុងថ្នាក់រៀនវិញ ទុកឱ្យខ្ញុំនៅឈរឡេមឡឺមម្នាក់ឯង។

ដូចខ្ញុំគិតទុក មិនដល់មួយម៉ោងផង ខ្ញុំត្រូវបានគេ Block ហ្វេសប៊ុកចោល។ ខ្ញុំចង់បកទៅថ្នាក់រៀននាងនិយាយហេតុផល តែដោយម៉ោងរៀនពេញពេក ខ្ញុំជាប់រវល់រហូតដល់ម៉ោងចេញ។

នៅតាមផ្លូវ ខ្ញុំឃើញនាងស្និទ្ធស្នាលនឹងនារីម្នាក់សម្បុរខ្មៅ។ ពេលពួកគេបែកផ្លូវគ្នា ខ្ញុំក៏រកឱកាសចូលទៅជិតនារីនោះ…

«សូមទោស មិត្តភ័ក្តិរបស់ណានីនមែន?»

ខ្ញុំដឹងពេលនោះថា នាងមានឈ្មោះចន្ទូ ជាអ្នកស្គាល់ជាមួយណានីនតាំងពីអនុវិទ្យាល័យ។ ខ្ញុំក៏អញ្ជើញនាងនិយាយគ្នានៅហាងកាហ្វេសាលា។

«ខ្ញុំចង់និយាយរឿងសំខាន់មួយជាមួយណានីន តែមិនបាននិយាយផង នាង Block ហ្វេសប៊ុកខ្ញុំបាត់!»

នាងញញឹមសួរខ្ញុំវិញភ្លែត៖

«ខ្លួនឯងតាមស្រលាញ់គេភ្លាវពេកដឹង?»

«អត់ទេចន្ទូ! ខ្ញុំមានបានធ្វើអីប៉ះពាល់កិត្តិយសគេ? ចន្ទូ ខ្ញុំដឹងរឿងមិនល្អមួយ ខ្ញុំខំប្រាប់គេពីដើមឈើដែលគេថតដាក់ក្នុង Profile ហ្វេសប៊ុក ដើមឈើនោះរាងដូចចម្លាមកៅស៊ូ វានាំមកនូវសំណាងអាក្រក់ដល់ណានីន ហើយបើវាជាផ្ទះរបស់នាង វាអាចជាបញ្ហាដល់គ្រួសារនាងទាំងមូល!»

ចន្ទូចាប់ផ្តើមភាំងសម្លឹងខ្ញុំ។ ខ្ញុំមិនចង់ឱ្យគេទុកខ្ញុំថាជាមនុស្ស «បែកៗ» ទាន់ទេ ខ្ញុំក៏និយាយពន្យល់បន្ថែម៖

«មិនមែនខ្ញុំនេះតាមស្រលាញ់គេ ហើយចេះតែរករឿងមកឱ្យតែបាននិយាយទេ ចន្ទូ! ខ្ញុំឆ្លងកាត់បទពិសោធខ្លួនឯង! បើនៅតែមិនជឿ ចាំខ្ញុំនាំមិត្តភ័ក្តិខ្ញុំមកជួយនិយាយ!»

«ខ្ញុំជឿតើ! និយាយមក ចន្ថា!»

ខ្ញុំសប្បាយចិត្តណាស់ ហើយក៏ចាប់ផ្តើមរម្លឹករឿងទាំងអស់ប្រាប់នាង។ នាងស្តាប់ ហើយក៏ផ្អែកខ្នងហាក់ភ័យ។

«ខ្ញុំចង់និយាយប្រាប់គេឱ្យដករូបហ្នឹងចេញ តែគេនៅសុខៗ ខឹងខ្ញុំដាច់ក្បាលដាច់កន្ទុយ ហើយ Block ខ្ញុំទៀត គិតមើល៍!»

ចន្ទូបើកទូរសព្ទរក Profile របស់ណានីនមកបង្ហាញខ្ញុំ ទាំងសួរបញ្ជាក់៖

«រូបមួយនេះមែនអត់ដែលខ្លួនឯងកំពុងនិយាយ?»

«ហ្នឹង!»

ខ្ញុំរលះរលាំងឆ្លើយ ទាំងផ្តោតភ្នែកលើរូបនោះ ព្រោះវាពិតជាច្បាស់ណាស់ មើលពីខាងណាក៏ដើមនោះបែកមែកធាងជាពីរធំៗរាងជាចម្លាមពិតៗ។

ចន្ទចុចបង្រួមពង្រីកពិនិត្យដើម្បីផ្ទៀងផ្ទាត់នូវអ្វីដែលខ្ញុំកំពុងនិយាយ។ វាចម្លែកចំពោះនាងពិតណាស់ ប្រសិនបើនាងមិនដែលដឹងអំពីរឿងនេះ ដូច្នេះហើយឆ្លៀតពេលដែលចន្ទនៅគិតសាចុះសាឡើង ខ្ញុំប្រឹងរកពាក្យនិយាយពន្យល់បន្ថែមបន្តបន្ទាប់ដែរ៖

«ហើយដើមហ្នឹងនៅក្នុងបរិវេណផ្ទះគេអត់? ចន្ទឯងដែលទៅផ្ទះគេអត់! បើវានៅក្រៅ មិនអីទេ គ្រាន់តែដូររូប Profile ចេញក៏បាន ប្រាប់គេអ៊ីចឹងទៅ តែបើនៅផ្ទះគេ...»

«ដើមនេះក្នុងរបងផ្ទះគេ ខ្ញុំដឹង ខ្ញុំឧស្សាហ៍ទៅតើ!»

ចន្ទគេឆ្លើយកាត់ផូង ហើយងើបមុខធ្វើភ្នែកម៉ក់ៗសម្លឹងខ្ញុំរបៀបទាល់គំនិត។ ខ្ញុំមិនរង់ចាំទេ ក៏ស្រូតនិយាយ៖

«គួរតែប្រាប់ពួកម៉ាកពីការពិត ហើយឱ្យគ្រួសារនាងរកគេមករំលើងចេញឱ្យបានមុនមានរឿងធំ!»

«រឿងធំ?»

«ចាស់ៗស្រុកខ្ញុំ គាត់ហាមដាច់ខាត! គាត់ថាដើមឈើដែលចេញរាងអ៊ីចឹងហើយ គឺមានព្រាយកាន់ហើយ! គេមិនឱ្យដាំក្បែរផ្ទះទេ!»

នាងនៅស្ងៀមដាក់ទូរសព្ទចុះយឺតៗ ហើយក្រេបកាហ្វេបន្លប់ក្តីខ្វល់ខ្វាយក្នុងចិត្ត។

«ខ្ញុំនិយាយនឹងគេមិនបាន ខ្ញុំ និងគេមិនដែលមានរឿងសោះ ម៉េចគេទុកខ្ញុំដូចជាសត្រូវ? នៅមិននៅ Block ខ្ញុំចោលទៀត?»

«ចាំខ្ញុំសួរឱ្យ! តែរឿង...អារឿងដើមឈើហ្នឹង ចន្ទាឯងដឹងពីណាមក ចន្ទាឯងច្បាស់ដែរអត់?»

ខ្ញុំនិយាយប្រាប់រឿងដែលខ្ញុំទើបនឹងបានជួបតាំងពីដើមរហូតដល់ចប់សូម្បីរឿងដែលមីងលក់សាំងបានឃើញខ្ញុំដឹកមនុស្សស្រី រឿងព្រាយតាមរកកូន ក្រោយមកខ្ញុំទៅដោះជាមួយតាជន្ទល់ខ្មៅ។ ចន្ទហាក់ព្រឺសម្បុរ ព្រោះសេចក្តីភ័យខ្លាច។ នាងអង្អែលកំភួនដៃខ្លួនឯងចុះឡើង ហើយឆ្លោយសម្តីសង្ស័យ៖

«អ៊ីចឹងដឹងបានអានីនថា បងប្រុសគេឈឺមិនបាត់ ឈឺដល់ទៅធ្វើការលែងបាន?»

ខ្ញុំសែនភ្ញាក់ផ្អើល ក៏ជជីកសួរភ្លាម៖

«ផ្ទះគេមានអ្នកឈឺហើយ?»

«ឈឺយូរហើយ ចន្ថា! ពេលនេះឮថាធ្ងន់ឡើងៗ ចន្ថាឯងមិនឃើញអានីនមុខមិនដែលស្រស់ទេអី?»

ខ្ញុំឮហើយ ពិបាកចិត្ត កាន់តែមិនដាច់ចិត្តពីនិស្សិតម្នាក់នោះសោះ។ ចិត្តស្រលាញ់ និងឈឺឆ្អាល បានបង្ខំឱ្យខ្ញុំដេកមិនលក់មួយយប់ទល់ភ្លឺ។ ព្រឹកឡើងមិនទាន់អីផង ចន្ធូឆាតមកទាំងព្រឹកថា «ចន្ថា! ខ្ញុំប្រាប់គេអស់ហើយ តែណានីនដូចជាខឹងចន្ថាឯងរឿងអីមិនដឹងទេ! គេថាគេមិនជឿល្បិចអស់ហ្នឹង! ខ្ញុំពិបាកដែរ ចន្ថា! មិនដឹងគួរទៅប្រាប់គេម៉េចទេ បើគេចេញមកអគតិជាមួយចន្ថាឯងតាម៉ង!»

បំណាច់ចិត្តស្រលាញ់ ខ្ញុំដាច់ចិត្តសួរចន្ធូរកផ្ទះគេ ហើយបបួលអាសាន់ឱ្យនាំទៅនិយាយនឹងពុកម៉ែគេតែម្ដង។ ពេលនោះល្ងាចហើយ គឺបន្ទាប់ពីចេញពីរៀន។ ខ្ញុំសម្រេចចិត្តទៅទាំងមិនបានសុំការអនុញ្ញាត ព្រោះមិនចង់ឱ្យខាតពេល។

តាមការគូសវាសប្រាប់របស់ចន្ធូ ខ្ញុំពិតជារកផ្ទះគេឃើញមែន ថែមទាំងឃើញដើមឈើដ៏ចម្លែកនោះ។ វាពិតជាមានរាងជាចម្លាមខ្មែងបែកជាពីរ គ្រាន់តែវាមិនធំទេ កម្ពស់ពីរដងមនុស្សចាស់ប៉ុណ្ណឹង។ ឃើញវាកាលណា ខ្ញុំព្រឺសម្បុរ។ បើកុំតែមកពីឥទ្ធិពលស្នេហា និងអាណិតឈឺឆ្អាលបងប្រុសនាង ខ្ញុំមិនហ៊ានប្រថុយមកប្រឈមមុខនឹងដើមឈើនេះធ្វើអ្វីនោះឡើយ។ អាសាន់ឌុបខ្ញុំសសៀរក្បែររបងផ្ទះនាងដែលអមពេញទៅដោយពពួកដើមឈើហូបផ្លែជាច្រើនដុះស៊ុបទ្រុបពិបាកក្នុងការសម្លឹងទៅក្នុងបរិវេណផ្ទះឱ្យបានច្បាស់លាស់ណាស់ តែខ្ញុំព្យាយាម ព្រោះក្រែងលោឃើញពុកម៉ែនាង ខ្ញុំនឹងជម្រាបពួកគាត់ភ្លាម។

«ពួកគេហ្នឹងហើយពូ!»

សំឡេងចម្រៃតរបស់នាងលាន់មកពីចម្ងាយ ធ្វើឱ្យខ្ញុំ និងអាសាន់ត្រូវប្រហមាត់ ព្រោះនាងបាននាំមុខប៉ូលិសពីរម៉ូតូមកដល់។

«ចុម អ្ហែងធ្វើអីកូនគេ គេនាំប៉ូលិសម៉ោអានេះ?»

អាសាន់សួរខ្ញុំទាំងភ័យដូចមាន់រកពង ចំណែកសមត្ថកិច្ចពិតជាបានឆ្ពោះសំដៅមករកពួកខ្ញុំពិតមែន។

«គេនេះហើយតាមខ្ញុំរហូត! គេនេះហើយ សរសេរឆាតមកជំរិតខ្ញុំ?»

អស់ពីឆ្ងល់ ខ្ញុំទៅជាស្រឡាំងកាំងនឹងពាក្យចុងក្រោយរបស់នាង «ជំរិត»?

ប៉ូលិសចុះស្រមក ហើយសំដៅមកកាក់ម៉ូតូពីរនាក់ខ្ញុំមិនឱ្យទៅណារួច។ ខ្ញុំខំនិយាយពន្យល់៖

«យល់ច្រឡំទេ បង!»

«ពួកអូនឯងមកលឺបលអីនៅរបងផ្ទះនេះ?»

ប៉ូលិសម្នាក់សួរសង្ឃើញមកខ្ញុំ។ ខ្ញុំមិនទាន់បានហើបមាត់ផង នាងឆ្លើយជំនួស៖

«ពូ! ចាប់គេទៅ ពូ! គេផ្ញើសារមកគំរាមខ្ញុំ ទាំងមិនដឹងរឿង ហើយតាមខ្ញុំនៅសាលាបួនប្រាំថ្ងៃហើយ!»

ខ្ញុំបកស្រាយទាំងហួសចិត្ត ហើយសម្លឹងនាងចំៗ៖

«រឿងតាម ខ្ញុំតាមមែន តែគំរាមស្អី ខ្ញុំគ្មានទេ ក្រែងយើង Block ហ្វេសប៊ុកខ្ញុំ?»

នាងតមាត់មកទៀត៖

«ខ្ញុំ Block ព្រោះខ្ញុំដឹង! អ្នកឯងសរសេរមកគំរាមខ្ញុំថាមិនឱ្យគ្រួសារខ្ញុំបានសុខ ហើយក៏តាមដានខ្ញុំនៅសាលារហូត!»

នាងនិយាយមិនដូចមានពុតទេ តែអ្វីដែលខ្ញុំគិតឃើញ គឺខ្ញុំប្រហែលជាជាន់ដានគេ។ អាណាម្នាក់ទំនងជាបានគំរាមនាងពិតមែន ហើយខ្ញុំនេះមកតាមលបមើលនាងបានជាជាន់ដានចោរ។ យល់ថាខ្លួនឯងស៊យណាស់ តែបានប្រឹងប្រាប់ប៉ូលិសដែរ៖

«ខ្ញុំអត់ទាក់ទងទេ! ខ្ញុំមកជួបឪពុកម្ដាយនាងរឿងដើមឈើនុះ!»

ប៉ូលិសសម្លឹងតាមចង្អុលដៃខ្ញុំទៅកាន់ដើមឈើដែលនាំបញ្ហា។ អាសាន់ចេញអេះក្បាលទាល់ ព្រោះវាដឹងថាហេតុផលរបស់ខ្ញុំបានត្រឹមឱ្យប៉ូលិសសើចចំអកលេងតែប៉ុណ្ណោះ។

ទីបំផុត ពួកខ្ញុំឃើញម្ដាយនាងរុញទ្វារចេញមក ខ្ញុំក៏និយាយទៅរកគាត់៖

«មីង ដើមឈើនោះហើយជាមូលហេតុធ្វើឱ្យកូនមីងឈឺមើលមិនជា!»

ម្ដាយនាងនៅស្ដាប់ទ្រឹង ខ្ញុំបានចិត្ត ក៏និយាយរ៉ាវៗនូវការពិតទាំងអស់នោះ។ ចុងក្រោយ ពេលម្នាក់ៗនៅឈរគិត ខ្ញុំងាកទៅនិយាយនឹងនាង៖

«ណានីន ខ្ញុំតាមដានយើងមែន ព្រោះខ្ញុំឃើញរូបណានីនថត Post ក្នុងហ្វេសប៊ុកជាមួយដើមឈើមួយនេះ បានជាខ្ញុំចិត្តល្អចង់ប្រាប់ ចំណែកអា Fake Account ណាមួយដែលបានឆាតគំរាមយើង ប្រគល់ Account នោះឱ្យប៉ូលិសទៅ គេគង់តែរកឃើញទេ!»

ពួកគេបានឮ ហើយក៏យល់ស្របគំនិតខ្ញុំដោយដូរទិសដៅទៅសម្លឹងនាងវិញព្រមៗគ្នា។ ស្ថានភាពនាងគឺមកតែពីកើតចិត្តខឹងខ្លាំងពេកពីអ្នកណាម្នាក់ដែលបានឆាតគំរាមនាង ដូច្នេះហើយមើលទៅសភាពនាងក៏មិនច្បាស់ខ្លួនឯងដែរ។

ពុកនាងជិះម៉ូតូមកដល់ គាត់ចុះមកសួរនាំ។ ពេលនាងបង្ហាញឆាតគំរាម គាត់ហាក់ភ្ញាក់ផ្អើល ហើយថ្លោះទឹកមុខ។ គាត់អញ្ជើញប៉ូលិសចូលក្នុង។ ណានីនចូលក៏ទៅតាមដោយមិនទាំងនិយាយសុំទោសខ្ញុំអីមួយម៉ាត់ណា។

ចំណែកខ្ញុំ និងអាសាន់នៅព្យាយាមពន្យល់ម្ដាយនាងមាត់របង។

គាត់នៅទីទើរស្ដាប់ ព្រោះប្រហែលជាគាត់គិតពីជំងឺកូនប្រុសតែប៉ុណ្ណោះ បើពុំនោះទេ ពួកខ្ញុំប្រាកដជានឹងគ្មានឱកាសនិយាយអ្វីច្រើនដូចពេលនេះឡើយ។

«ហេតុអីក្មួយៗប្រាកដចិត្តថាសន្និដ្ឋាននេះត្រូវ?»

នេះជាសំណួរតែមួយគត់ដែលគាត់សួរខ្ញុំ។ ខ្ញុំក៏ចំណាយពេលនិយាយរឿងគ្រប់យ៉ាងឱ្យគាត់ស្ដាប់ពីដើមដល់ចប់។ ចុងក្រោយ គាត់សុំឱ្យខ្ញុំទាក់ទងឱ្យគាត់បាននិយាយជាមួយម្ដាយខ្ញុំតាមទូរសព្ទ។

ខ្ញុំយល់ថា ទំនងជាគាត់ចង់រកគ្រូពូកែឱ្យជួយមកមើលសិន មុនពេលជឿសម្ដីខ្ញុំកាប់ឈើនោះចោល។ ខ្ញុំធ្វើតាមគាត់ដោយយកលេខមក ហើយសន្យាថាឱ្យម៉ែខលមកនិយាយនឹងគាត់យប់នេះ ខ្ញុំត្រូវការពេលជម្រាបម៉ែពីដំណើរដើមទងសិនដែរ។

គាត់ស្ដាប់ ហើយឱ្យលេខមក និងអរគុណពួកខ្ញុំ ហើយឱ្យពួកខ្ញុំវិលទៅវិញសិន។

នៅតាមផ្លូវវិលទៅកុដិ អាសាន់សួរខ្ញុំ៖

«អ្ហែងគិតថាមីងហ្នឹងព្រមកាប់ដើមហ្នឹងចោលអត់?»

«គាត់ជឿហើយ បានជាឱ្យលេខមកយើង!»

«ចុះឯងប្រុងឱ្យម្ដាយឯងតេទៅគាត់មែន? ក្រែងតាជន្ទល់ខ្មៅមិនឱ្យអ្នកណារម្លឹករឿងព្រាយដើមឈើនោះទៀត មិនអ៊ីចឹង?»

«អញគិតថាជួយមនុស្សជារឿងសំខាន់! ចាំអញអង្វរម៉ែសិន! ចាំមើលមើល៍ គាត់ថាម៉េច? បងប្រុសណានីនប្រហែលឈឺធ្ងន់ណាស់ហើយ អ្ហែងមើលតែទឹកមុខម៉ែរបស់នាងទៅ!»

អាសាន់និយាយឌឺខ្ញុំភ្លាម៖

«អ្នែងនេះស្រលាញ់គេឡើងយ៉ាប់ខ្លួនហើយអ្នា!»

ខ្ញុំលែងមាត់ តែបេះដូងខ្ញុំពិតជាគិតដល់គេពិតមែន វាប្រៀបដូចជានិស្ស័យអ្វីមួយយ៉ាងអាថ៌កំបាំងណាស់។ បន្ទាប់ពីនោះមក គ្រប់យ៉ាងស្ងាត់បាត់ ព្រោះស្នែកឡើងជាថ្ងៃសម្រាក។

ខ្ញុំខលសួរម៉ែ គាត់ថា គាត់បានទាក់ទងទៅប្រាប់រឿងដើមឈើរាងដូចចម្លាមនោះហើយ គាត់ថាខាងនោះពិតជាចាប់អារម្មណ៍ខ្លាំងមែន។ ឮហើយ ខ្ញុំហាក់ធូរចិត្តច្រើន។ ដែលរឹតតែអស្ចារ្យនោះ ស្នែកល្ងាច នាងស្រាប់តែដក Block ចេញបាត់ ថែមទាំងមក Add Friend ខ្ញុំទៀត។

«ចន្ថា ខ្ញុំសុំទោស ខ្ញុំយល់ខុសលើចន្ថាឯង! តាមពិត ប៉ូលិសរកឃើញហើយថា Account នោះមិនមែនចន្ថាឯងទេ! សុំទោសណាចន្ថា ខ្ញុំសុំទោសពិតមែន!»

រំលងបានមួយថ្ងៃ ស្រាប់តែនាងមករកខ្ញុំដល់ថ្នាក់រៀនតែម្តង គឺមកជាមួយចន្ទូ។ ពេលនោះម៉ោង ៩ ព្រឹកប៉ុណ្ណោះ។

នាងធ្វើមុខស្លូយៗ ពេលនិយាយជាមួយខ្ញុំដូចជានាងបាក់ខ្លបខ្លាចលើរឿងអ្វីមួយ ខុសស្រឡះពីកាលដែលទើបនឹងជួបគ្នាដំបូង។

«មានរឿងអីពឹងចន្ថា ឯងឆាប់និយាយទៅ នាង!»

ត្រូវមិត្តតឿន ណានីនក៏ផ្តើមនិយាយតិចៗ ហើយស្រងូត៖

«ខ្ញុំមានរឿងបន្ទាន់ចង់ឱ្យចន្ថាឯងជួយ! ចន្ថាទៅជួបម្តាយខ្ញុំជាមួយខ្ញុំបន្តិចបានទេ?»

មិនបាច់គិតច្រើនទេ ខ្ញុំក៏យល់ព្រមភ្លាម។

**វគ្គ**

**អ្នកជំងឺ**

ពួកយើងចេញទៅផ្ទះនាងនៅម៉ោង ១០ ព្រឹក គឺសុំគ្រូចេញ ព្រោះនាងថាបន្ទាន់បំផុត។

លើកនេះមិនមែនដូចលើកមុនទេ គឺខ្ញុំ និងអាសាន់ជាភ្ញៀវដែលត្រូវបានគេអញ្ជើញឱ្យចូលក្នុងផ្ទះត្រឹមត្រូវ លែងនៅលឹបលក្បែររបងដូចមុនទៀតហើយ។

ផ្ទះរបស់គ្រួសារណានីនជាប្រភេទផ្ទះឈើចាស់រាប់សិបឆ្នាំមកហើយ។

របងផ្ទះនាងធំ បើលក់ ក៏បានថ្លៃច្រើន ព្រោះនៅជាយក្រុងភ្នំពេញ។ សំខាន់ ផ្ទះនេះហាក់ស្ងាត់ស្រងេះស្រងោចណាស់។ ដែលរឹតតែភ្ញាក់ផ្អើល គឺគេរំលើងដើមឈើមួយនោះបាត់ទៅហើយ គឺរំលើងដល់ឫស នៅសល់តែស្លាកស្នាមជ្រៅខូងធំគួរឱ្យខ្លាច។

អ្វីដែលខ្ញុំឆ្ងល់ឥតអាក់ គឺបើគេសម្រេចចិត្តរំលើងឈើនោះចោលហើយ តើគេរកខ្ញុំមានការអ្វីទៀត?

អ្វីដែលខ្ញុំបានឃើញដំបូងគេ គឺបងប្រុសនាងដែលដេកឈឺស្លូកព្យួរសេរ៉ូមលើដៃ។

បើគ្រួសារនាងព្រមធ្វើតាមអាគមផ្សំអាយុសហើយ បុរសនេះគួរតែបានធូរ?

«គាត់ឈឺមិនធូរសោះ?»

ខ្ញុំសួរ ពេលឱនដោះស្បែកជើង ស្រាប់តែនាងឆ្លើយវិញភ្លែតៈ

«មានហ្អា គាត់ធូរច្រើនហើយ បានពេទ្យឱ្យចេញមកសម្រាកផ្ទះ! មុនដាច់បាយពីរថ្ងៃហើយ ព្រឹកមិញម៉ែថា គាត់ហូបបបរបានពេញមួយចាន!»

បងប្រុសនាងងៀងមកសម្លឹងខ្ញុំ ខ្ញុំឱនគោរពគាត់ រួចក្រឡេកឃើញគាត់ញញឹម។

វាជារឿងយ៉ាប់ណាស់ដែលយុវវ័យជានិស្សិតដូចខ្ញុំមកជឿ និងសាបព្រោះរឿងអស់ទាំងនេះ ប៉ុន្តែប្រសិនកាប់រំលើងដើមឈើដែលចាស់ៗសង្ស័យថាមានព្រាយតាំងលំនៅ អាចជួយបងប្រុសនាងបានពិតមែននោះ ខ្ញុំក៏គ្មានរឿងអីត្រូវទោមនស្សដែរ។

«ឡើងផ្ទះមក!»

ម្ដាយនាងហៅមកពីលើ។

ខ្ញុំ និងអាសាន់ឡើងទៅជាមួយចន្ធូ ចំណែកណានីនអង្គុយជូតមុខមាត់ឱ្យបងប្រុសនាង។ តាមផ្លូវឡើងជណ្ដើរ ខ្ញុំលួចកេះសួរចន្ធូៈ

«គេមានតែពីរនាក់បងប្អូនទេអី?»

«ហ្នឹងហើយ! ពីរនាក់បងប្អូនគេស្រលាញ់គ្នាណាស់! បងប្រុសនាងជាបង្គោលគ្រួសារទៅរកស៊ីនៅព្រំដែន ចុងក្រោយឮថាក្រឡាប់ឡាន! មានតែគាត់ទេ រស់! គាត់ឈឺយូរហើយ រាប់ខែហើយ អស់លុយមិនតិចទេ ចេញចូលពេទ្យដូចផ្ទះ!»

ខ្ញុំភ័យក្រញាងនឹងដំណឹងអស់នេះ។ មិនអ៊ីចឹង នារីដ៏ស្អាតនេះមិនធ្វើមុខស្រពោនជានិច្ចនោះទេ។ តើវាជានិស្ស័យដែរអីដែលឱ្យខ្ញុំឃើញគេ ហើយប្រទះឃើញដើមឈើនេះនៅក្រោយរូបថត Profile របស់គេ? សម្លឹងទៅកាយវិការគេជាមួយនឹងបងប្រុសធ្វើឱ្យខ្ញុំកក់ក្ដៅ ហើយអាណិតគ្រួសារនេះទ្វេ។

ទោះបីជាយ៉ាងណា ខ្ញុំរកមើលមិនឃើញវត្តមានរបស់លោកពុកនាងសោះ។

ខ្ញុំឡើងជិតដល់លើ ក៏នឹកឃើញចង់ដៀងភ្នែកទៅសម្លឹងសំណល់ពីការរំលើងដើមចម្ពាម។ ហេតុអីគ្មានឃើញសល់ធូបទៀនមួយសរសៃណាក្បែរគល់ដ៏រូងនោះ?

ពេលមួយក៏អត់សល់? គេមិនសមថាធ្វើបរព្រៃហើយ រៀបចេញចោលបានរហ័សម្ល៉េះ? ផ្កាក្រៀមមួយទងក៏មិនឃើញ?

«មុនរំលើងយកឈើហ្នឹងចេញ គេមានធ្វើពិធីអីអត់ហ្នឹង?»

ខ្ញុំងាកសួរខ្សឹបខ្សៀវជាមួយគ្នាខ្ញុំ ប្រហែលជាពាក្យខ្ញុំទាំងប៉ុន្មានឮដល់លើផ្ទះទាំងអស់បានជាពេលនោះ ម្ដាយគេនិយាយតចុះមកវិញជំនួសចន្ទ្ធ៖

«អត់ទេកូន! អត់បានធ្វើអីទាំងអស់!»

ចិត្តខ្ញុំភាំង ហើយជើងក៏គាំងនៅត្រឹមមាត់ទ្វារ។ ម្ដាយបង្ហាញខ្លួនជាមួយទឹកមុខព្រួយកង្វល់ភ្នែកទាំងគូរូងជ្រៅដូចជាមិនបានគេងមួយស្រលេតណាទេយប់មិញ។

គាត់បន្ថែមមកកាន់ខ្ញុំ៖

«អ៊ីចឹងហើយបានជាមានរឿង!»

ម្ដាយនាងខ្សឹបទាំងទាញដៃខ្ញុំឱ្យចូលក្នុងផ្ទះក្រោមភាពភ្ញាក់ផ្អើលរបស់ខ្ញុំ និងអាសាន់ ចំណែកឯចន្ទ្ធនាងថយទៅអង្គុយមិនមាត់មិនកលើសាឡុងឈើ ព្រោះនាងហាក់ដឹងរឿងច្រើនជាងពួកខ្ញុំ។

«មានរឿងអីទៅ មីង?»

អាសាន់លាន់មាត់សួរ ព្រោះវាស្ងាត់យូរហើយ។ មីងងាកទៅរកម្ចាស់សំណួរ ទឹកមុខគាត់គឺទាក់ទើរស្ទើរលាក់ស្ទើរសារភាព។

គាត់ហាក់ទទួលស្គាល់ថាខ្លួនបានធ្វើអ្វីម្យ៉ាងខុស តែមិនដឹងដោះស្រាយបែបណា?

ស្នូរជើងណានីនឡើងមកតាមពីក្រោយ។

ខ្ញុំឃើញនាង ក៏នឹកឃើញរេរកមើលពុកនាង។

«ពូនៅឯណា?»

ម្តាយកូនសម្លឹងមុខគ្នាទៅវិញទៅមក។ ចន្ទជាអ្នកឆ្លើយ៖

«ពូនៅពេទ្យនៅឡើយ! តាំងពីគាស់គល់ ហើយគាត់គ្រាំទ្រូងក្អកធ្លាក់ឈាមមិនបាត់ទេ!»

ស្ថានការណ៍បែរទៅជារន្ធត់សម្រាប់ខ្ញុំ និងមិត្ត។ ពីរនាក់យើងត្រូវសំងំធ្មឹងតែម្តង ព្រោះមិនយល់អ្វី។

«មីងចង់ទូរសព្ទទៅរកម្តាយរបស់ក្មួយ តែខ្លាចចិត្ត ខ្លាចគាត់បន្ទោសដែលមិនព្រមធ្វើឱ្យត្រឹមត្រូវតាមពាក្យគាត់!»

ខ្ញុំកាត់យល់បានតិចៗហើយ គ្រួសារនេះប្រហែលជាខលទៅម៉ែខ្ញុំ គ្រាន់តែឱ្យបានប្រាកដពីរឿងដើមចម្លាមតែប៉ុណ្ណឹង ពេលគាត់ជឿថាវាពិតជាមិនល្អមែន គាត់ក៏សម្រេចចិត្តដករំលើង តែប្រហែលជាមិនបានធ្វើពិធីបរព្រៃទេ។

«មីងអត់សែនបរព្រៃសិនទេ ពេលដក?»

ខ្ញុំសួរភ្លែតតាមសន្ទុះចិត្តសង្ស័យ ឯគាត់ក៏ជ្រប់មុខមិនស្តី បានន័យថាព្រមទទួលស្គាល់សេចក្តីសន្និដ្ឋានរបស់ខ្ញុំ។

ហួសចិត្ត តែខ្ញុំអត់ធ្មត់ ហើយសួរគាត់បន្ថែម៖

«ចុះម៉ែខ្ញុំគាត់ជម្រាបមីងតែពីរឿងដើមចម្លាមត្រូវកាយគាស់ចេញ តែមិនបានប្រាប់ពិធីបរព្រៃអីទេ?»

«គាត់ប្រាប់ដែរ! តែមីង និងពូឯងចចេសមិនព្រមធ្វើ ណាមួយសោហ៊ុយអញ្ជើញគ្រូពីនោះមក គេមិននិយាយទ្រនឹប តែខាងភ្លេង អ្នកចូលរូប និងអាចារ្យរៀបគ្រឿង គិតដល់ទៅ ៥០០ ដុល្លារ នៅវណ្តាប់គគោកទៀត! គិតចុះគិតឡើង មីង និងពូមូលចិត្តថា នេះជាទម្លាប់ស្រុកផ្សេង អ្នកនៅទីនេះគេមិនដែលទម្លាប់ធ្វើផង យើងក៏នឹកឃើញថាខ្ជិលចង់ទម្លាប់ ឃើញគេគាស់រំលើងសង់ផ្ទះមួយគំនរ មិនចេះកើតអី ក៏សម្រេចតាមហ្នឹងទៅ!»

«តែឈើគេ ឈើធម្មតា ឈើមីង មានគេនៅ!»

ខ្ញុំភ្លាត់មាត់និយាយដូចជាខ្លួនឯងហ្នឹងអ្នកជឿលើរឿងអស់នេះណាស់។ តាមពិតទៅ ខ្មាសគេដែរដែលជាយុវវ័យទាន់សម័យ ហើយមកនិយាយស្តីធ្វើមើលតែខ្លួនជាពួកងប់ជំនឿស៊ុប។

ចន្ទជួយនិយាយបន្ថែមៈ

«ឥឡូវពូប្រហែលខុសអីហើយ គាត់ធ្លាក់ឈាមគ្រាំមិនឈប់! ចង់ឱ្យចន្លាឯងជួយឱ្យបានគ្រូធំនោះមកដោះអាសន្នឱ្យគាត់!»

ខ្ញុំទើបនឹងដឹងការពិតពីមូលហេតុដែលម្ដាយនាងចង់ជួបខ្ញុំ គឺគាត់ចង់ឱ្យខ្ញុំ និងអាសាន់ជូនទៅរកគ្រូនៅស្រុកសោះ។

ខ្ញុំងាកមើលមុខគ្នាសាជាថ្មី។ បើមិនធ្លាប់ឆ្លងកាត់ជាក់ស្ដែងខ្លួនឯង ខ្ញុំមិនដែលគិតថាស្ថានភាពប្ដីគាត់ក្នុងពេលនេះគឺគ្រោះថ្នាក់ធំឡើយ។

«មីងសារភាពថា ប្ដីមីងគាត់រាងមានះ! មិនព្រមហៅអ្នកណាមកទេ! មីងឱ្យហៅឡានមកទាញទៅ គាត់ថាឈើតូចប៉ុណ្ណឹង គាត់ធ្លាប់កាប់ចោលច្រើនជាងហ្នឹង ១០ ដង! គាត់កាប់មិនអីផុនគាត់មែន តែពេលរុកគាស់រំលើងគល់ បានធ្ងន់! គាត់ប្រឹងគាស់ម្នាក់ឯងគត់ ព្រោះកូនប្រុសរវល់ដេកឈឺ! ឥឡូវនេះ គ្រាំឈឺក្អកធ្លាក់ឈាមដោយគ្មានមូលហេតុ! ពេទ្យបូមឈាមទៅតេស្តផង ឆ្លុះថតផង នៅតែមិនទាន់វិនិច្ឆ័យបានថាជាជំងឺអ្វី! មីងថាមានតែផ្លូវងងឹតហើយ!»

រឿងជាន់លើរឿង នៅមិននៅអ្នកមួយមិនទាន់ជា ម្នាក់ទៀតត្រូវចូលពេទ្យ? ងាកទៅនាង នាងសែនកើតទុក្ខ តោងដៃម្ដាយ ហើយជ្រប់មុខ។ ខ្ញុំដឹងថា នាងចង់បានជំនួយណាស់ក្នុងពេលនេះ។

ខ្ញុំក៏ថយមកពិគ្រោះនឹងអាសាន់។

«អញរវល់ អ្អែងក៏រវល់ ទៅម៉េចបានអាថា?»

ទោះអាសាន់មិនបដិសេធ ក៏រឿងទៅរកតាជន្ទល់ខ្មៅ ខ្ញុំមិនចង់ទៅស្រាប់ហើយ ព្រោះនឹកដល់ពាក្យគាត់ធ្លាប់ផ្ដាំថា បើខ្ញុំរួចពីព្រាយដើមបំពេញរាជ្យហើយ ខ្ញុំត្រូវបំភ្លេចរឿងនេះចោល មិនឱ្យរម្លឹកឡើងវិញទេ។ ហេតុតែស្រលាញ់កូនគេ ខ្ញុំបានបំពាន។

ខ្ញុំតឹងទ្រូងណាស់ ចិត្តមួយចង់ជួយស្រីស្អាត ចិត្តមួយខ្លាចភ័យដែរ។ ខ្ញុំរអ៊ូនឹងពួកម៉ាកៈ

«តាជន្ទល់នៅឆ្ងាយពីភូមិអញ ហើយក៏មិនប្រាកដថាគាត់អាចមកបាន ឬព្រមដោះឱ្យអត់ទៀត! អ្អែងគិតមើលឈឺធ្លាក់ឈាម អញមិនដែលឮ? ទាល់តែម៉ែ! គិតខលទៅសួរម៉ែសិន!»

អាសាន់វាឱ្យយោបល់ៈ

«អ្អែងមិនទៅរកអាចារ្យមួយនៅផ្ទះជាន់ទីបី ដែលតាសឿននាំអ្អែងទៅកាលលើកមុននោះ អញចាំនៅក្រោមនោះ!»

ខ្ញុំនឹកឃើញដល់តាអាចារ្យឈ្មោះសច្ចា។ កាលណោះគាត់មើលត្រូវៗណាស់ ដែលគាត់ហ៊ានថាខ្ញុំនេះមានក្លិនសាច់ឆ្អែក្នុងខ្លួន ទើបខ្មោចអាចមកយាយីអុកឡុកបាន ចំណែកទៅដល់តាជន្ទល់ខ្មៅក៏និយាយមិនខុសគ្នាអីបន្តិច។

«កាលហ្នឹង អ៊ំអាចារ្យហ្នឹងគាត់ដូចជាគ្មានកម្លាំងដោះឱ្យ គាត់បានត្រឹមបិទភ្នែកមើលឱ្យអញ! ហើយដេញអញឱ្យទៅរកគេនៅស្រុក បានម៉ែអញធ្លាក់ដល់រកតាជន្ទល់ខ្មៅ!»

អាសាន់វាតបវិញ៖

«ចាំអញខលទៅអាចារ្យសឿន សុំលេខពួកម៉ាកគាត់ឱ្យ!»

«អត់ទេ! អញមានតើ! ចាំអញខល! គិតតិចសិនអានេះ កុំប្រញាប់ពេក!»

ចុងក្រោយ ខ្ញុំសម្រេចចិត្តថា នាំម្ដាយគេទៅជួបតាសច្ចា ក្រែងគាត់ជួយបាន ព្រោះគាត់ថាគាត់ទទួលមើលឱ្យ ណាមួយគាត់ក៏នៅជិតស្រាប់។ ពេលខ្ញុំទាក់ទងទៅ គាត់ក៏សុំដឹងដំណើរដើមទង។

សំណាងល្អ តាសច្ចាហាក់បានគ្រាន់ពីជំងឺជាងមុនបានជាគាត់ព្រមទទួលថាជួយ ប៉ុន្តែគាត់ត្រូវការនិយាយនឹងម្ចាស់ដើមឈើផ្ទាល់ គឺអ្នកកាប់សិន ទើបគាត់ដឹងថាមានវិធីអ្វីខ្លះ។

ដំបូង ពុកណានីនមិនយល់ព្រមនិយាយនឹងអាចារ្យទេ តែដោយសារបាននាងអង្វរករ ទើបគាត់យល់ព្រម។ ពេលនោះម៉ោង ៣ រសៀលទៅហើយ។ ទោះយ៉ាងណា អាចារ្យសច្ចាពិតជាមនុស្សចាស់ទុំគួរឱ្យគោរពបំផុត។ ពេលបានដឹងរឿងហេតុហើយ គាត់ប្រាប់ថា ត្រូវធ្វើពិធីជាបន្ទាន់ មិននិយាយពីរឿងលុយកាក់អ្វីទាំងអស់ ដឹងតែឱ្យពួកខ្ញុំទៅទទួលគាត់ពីវត្ត មិនមែនពីផ្ទះគាត់ជាន់ទីបីនោះទេ។

ណានី និងចន្ទូក៏ត្រូវទៅទទួលឪពុកនាងមកផ្ទះសិនដែរ។

ខ្ញុំបានមកដល់វត្តនៅរសៀលម៉ោង ៤ ជាងទៅហើយ។ អាចារ្យសច្ចាបានរៀបបង្វេចរង់ចាំហើយជាស្រេចដោយមានអាចារ្យពីរនាក់ផ្សេងទៀតមកជាមួយគាត់ ដៃមានកាន់ពៃ និងរណ្ដាប់ជាដើមចេកគ្រប់មុខផង។

«តោះ! កុំឱ្យខាត ត្រូវរៀបចំពិធីទាំងយប់!»

ម្ដាយណានីនក្រាលកន្ទេលពេញលើផ្ទះ ហើយមានញាតិមិត្តបងប្អូន និងញាតិជិតខាងចេញចូលជួយប្អូនដប់នាក់ដែរ គ្រាន់តែថាមិនច្រើនអ៊ូអរដូចនៅស្រុកស្រែទេ ព្រោះអ្នកភ្នំពេញសុទ្ធតែរវល់កប់ព្រលប់ ណាមួយគេមិនសូវជាស្គាល់គ្នាស្និទ្ធថ្នាក់ហ៊ានហៅគ្នាមកចូលរួមពិធីប្លែកៗអ៊ីចឹងដូចនៅតាមស្រុកភូមិឡើយ។

ពិធីរបស់តាសច្ចាមហាប្លែកទៀតហើយ។

ខ្ញុំតាមមើលរហូត ក្រែងគាត់ប្រើឱ្យទៅទិញក្អមអង្ករ និងរកកំបោរដូចកាលតាជន្ទល់ខ្មៅ តែអត់សោះ គាត់បែរជាបង្គាប់ឱ្យរកបេះផ្កាចម្ប៉ាពិតៗ ទឹកអប់ក្រអូប ហើយក្លិនប្រុស គាត់មិនព្រមរើសយកក្លិនណាផ្អែមឆ្អួលបែបមនុស្សស្រី។

នៅពេលបានរបស់ហើយ គាត់ធ្វើការស្និទ្ធស្នាធ៏ដូចពីកាលតាសឿននាំខ្ញុំទៅផ្ទះគាត់ដំបូងដែរ។ ឪពុកម្ដាយណានីនអង្គុយបត់ជើងលើកន្ទេលរង់ចាំ ចំណែកអាចារ្យពីរនាក់ទៀតញាប់ដៃជើងរៀបចំពៃ ដោយបង្គាប់ឱ្យញាតិមិត្តរកបង្អែម និងចម្អាបបន្តិចបន្តួចមកឱ្យហើយ។

តាមមើល ទោះមិនទាន់សមាធិដឹង ក៏គេត្រៀមក្នុងការធ្វើពិធី ព្រោះថ្ងៃជិតលិចមែនទែនហើយ។ ស្ថានភាពពុករបស់ណានីន គឺគាត់ស្រពាប់ស្រពោន បៀមទុក្ខព្រួយមិនសូវនិយាយមិនសូវស្ដីឡើយ។ ពេលត្រូវបានតាសច្ចាបង្គាប់ឱ្យអុជធូប គាត់ខំប្រឹងទប់ខ្លួន អុជហើយ ផ្សងរអ៊ុះៗតែម្នាក់ឯងមិនមានអារម្មណ៍និយាយរាក់ទាក់លេងនឹងអ្នកណាទាំងអស់។

បានធូបជះក្លិនពេញផ្ទះកាលណា តាអាចារ្យពីរនាក់បាញ់ទឹកអប់បន្ថែមក្លិនចាស់ផ្អែមស្អិតសឹងឈ្លក់បាន។ ពេលនោះហើយ តាសច្ចាទន្ទេញធម៌ញាប់ស្មេ ហើយនិយាយភាសាអ្វីដូចពួកកូនក្មេងយឺតៗអន្លាយៗ ញ៉េកៗស្រួយស្រើប។

គ្រប់គ្នាស្ងាត់ច្រៀបនៅព័ទ្ធជុំវិញគាត់។ មិនយូរប៉ុន្មាន គាត់រលត់សំឡេងឈឹងទៅដូចលង់ក្នុងសមាធិ។ គាត់បិទភ្នែកស្ងាត់បានមួយស្របក់ ហើយបានតាពីរនាក់ចាប់ផ្ដើមស្រែកដាស់ហៅ៖

«ក្រោកមកវិញមក តាអើយ!»

តែប៉ុន្មានម៉ាត់នេះសោះ តាសច្ចាក៏ភ្ញាក់ញ័រអស់ខ្លួន ហើយដឹងខ្លួនច្រងាងមកវិញ។ គាត់បើកភ្នែកសម្លឹងឪពុកនាងយ៉ាងមុត ធ្វើឱ្យពុកណានីនឈ្ងោកមុខគេចភ្នែកគាត់។

«បណ្ដេញអ្នកផ្សេងចេញឱ្យអស់ ទុកតែពីនាក់ប្ដីប្រពន្ធនេះ និងចន្ថាឱ្យនៅ!»

គាត់បង្គាប់ទៅគ្នាគាត់ឱ្យសុំអ្នកផ្សេងចាកចេញទៅក្រោមផ្ទះ នៅមុខគាត់ មានតែខ្ញុំ និងប៉ាម៉ាក់នាង។

ស្ងាត់មនុស្សអស់ គាត់ចាប់ផ្ដើមបន្ថើរសម្ដីនិយាយប្រាប់ខ្សឹបៗ៖

«អ្នកមួយដែលគេទំនៅនឹងដើមនេះយូរមកហើយ គេមិនសុខចិត្តដែលប្អូនឯង នៅមិននៅទៅកាប់ទន្ទ្រានរើរុះគេ! មុនពេលកាប់រំលំដើមឈើណាមួយ ត្រូវធ្វើពិធីបវាស ឱ្យគេចេញមុន សឹមយើងរុះចោលក្រោយ! ឥឡូវគេមិនសប្បាយចិត្ត គេត្រូវការឱ្យឯងសងឈើគេ!»

ម្ដាយនាងឃើញស្វាមីឈ្ងោកមិនព្រមនិយាយអ្វី គាត់ក៏ព្រមអារកាត់៖

«សុំតាអាចារ្យជួយផង!»

តាសច្ចាបង្គាប់ប្រាប់៖

«វិធីសុំខមាទោសគេ គឺមានតែធ្វើឱ្យគេសប្បាយចិត្ត ទើបយើងអាចបរព្រៃបញ្ជូនឱ្យគេចេញទៅឆ្ងាយភ្លេចផ្លូវវិលមកវិញ ខ្ញុំស្មិងស្មាធិ៍សួរគ្រូធំពីវិធីឱ្យច្បាស់សិន!»

គាត់ធ្វើដៃទាររកថាសផ្កាចម្ប៉ា។ អាចារ្យម្នាក់ហុចឱ្យគាត់ គាត់ក៏កាន់ថាសផ្កាជាប់ ហើយអង្គុយបន្តស្មិងស្មាធិ៍។ គ្មានអ្នកណានិយាយអ្វី ឬប្រើភ្លេងអ្វីទាំងអស់។ អាចារ្យពីរនាក់គិតតែពីដុតធូបបន្តមិនឱ្យដាច់ ហើយបាញ់ទឹកអប់ច្រូចៗពាសពេញទីប្រារព្ធពិធី។

មិនយូរប៉ុន្មាន តាសច្ចាកន្ត្រាក់ខ្លួនសាជាថ្មី ហើយបើកភ្នែកខ្វាច់ងាកមកគំហក៖

«តាឯងមានអីលាក់អញ?»

ពុកណានីនដំបូងមិនដឹងថាតាសច្ចាសម្លឹងគាត់ទេ ព្រោះគាត់គិតពីសំពះឱនមុខជ្រប់ តែពេលប្រពន្ធកេះ គាត់ងើបមុខមកប្រឈមនឹងកែវភ្នែកក្រឡោតៗរបស់តាសច្ចា។ កុំថាពុកនាង ខ្ញុំឯណោះ ក៏បះសក់ច្រូងនឹងអាការៈផ្លាស់ប្ដូរទៅជាមនុស្សផ្សេងក្នុងខ្លួនតាសច្ចាដែរ។

ពុកណានីន មីងមាំងមិនដឹងថាគេកំពុងសួរអ្វី តែអាចារ្យមួយរូបជាគ្នីគ្នាឱនមកកេះខ្សឹបប្រាប់៖

«នេះមិនមែនគាត់ទេ គ្រូធំគាត់ចូលមកហើយ ស័ក្តិសិទ្ធណាស់ គាត់សួរអីឆ្លើយនឹងទៅ គាត់អាចជួយបានទាំងអស់ សូមគាត់ទៅ!»

ខ្ញុំព្រឺសម្បុរទ្រាំលែងបាន ត្រូវតែអង្អែលកំភួនដៃខ្លួនឯង។ តាសច្ចាមាត់ទំពាផ្កាចម្ប៉ាសញ៉ាច់ៗ ហើយលេបចូលពោះក្អឹកៗដូចជាអាហារដ៏មានឱជារស។

ខ្ញុំឆ្លងកាត់ពិធីបុរាណខ្មែរច្រើនណាស់ តែមិនដែលឃើញអ្នកណាចូលរូបច្បាស់ដល់ថ្នាក់នេះទេ។ ពេលនេះ តាសច្ចាលែងជាខ្លួនគាត់ដែលខ្ញុំធ្លាប់ឃើញហើយ ប៉ុន្តែគាត់លើកស្មាឡើងខែងរ៉ែង ហើយអង្គុយត្រង់ខ្លួនពែនហំហាន ដូចសភាពពួកនាម៉ឺនបុរាណដែលអង្គុយជុំគ្នាឯសាលាជំនុំ ខ្ញុំឃើញតែក្នុងល្ខោន។ ម្ហូបផ្កាកាន់តែហោចទៅៗ អាចារ្យម្នាក់ទៀតតឿនៈ

«តោះម្ចាស់ផ្ទះ សូមគាត់ឱ្យជួយឱ្យហើយទៅ! តែរូបចេញបាត់ ពិបាកហៅមកវិញណាស់! ឆាប់ឡើង!»

ម្ដាយនាងរលះរលាំងនិយាយទាំងសំពះញ័រៈ

«ឱបរមី! ប្ដីខ្ញុំធ្លាក់ឈាមមិនបាត់ទេ! សូមជួយគាត់ និងកូនប្រុសច្បងខ្ញុំ សុំគ្រួសារនេះបានសុខសួស្ដីត្រឡប់មកវិញ!»

«តានេះ យករបស់គេលាក់! បើប្រញាប់មិនសងវិញគេទេ ជីវិតក្រែងតែពុំគង់!»

រូបនោះគំហកធ្វើឱ្យពុកណានីនចាប់ផ្ដើមញ័រដៃ។ គ្រប់គ្នាសម្លឹងមកគាត់ដូចផ្ទាំងស៊ីប។ ភរិយាមុខចង់យំក៏យំមិនចេញ គាត់តឿនប្ដីសួរៈ

«ឯងលាក់ស្អី ឆាប់និយាយមក!»

«របស់នោះ ខ្ញុំរកមិនឃើញទេ វាមិននៅនឹងខ្ញុំយូរហើយ!»

គាត់សារភាពញ័រៗ ធ្វើឱ្យខ្ញុំភាំង។ ខ្ញុំមិនដឹងគាត់និយាយពីរបស់អ្វី ហើយរបស់នោះជាអ្វីដែលរូបតាសច្ចាកំពុងថានោះដែរអត់?

ផ្កាអស់រលីងហើយ។

គ្មានមនុស្សធម្មតាឯណាហូបផ្កាចម្ប៉ាអស់មួយថាសក្នុងពេលប៉ុន្មានវិនាទីនោះទេ។ តាសច្ចាញីចិញ្ចើមដឹងខ្លួនវិញជាសញ្ញាថាអ្នកមានឫទ្ធិដែលឆាន់ផ្កាមុននេះបានហើរចោលគាត់។

«១២ ឆ្នាំមុន ខ្ញុំ និងអាកែម ពួកម៉ាករួមកងពល បានជីកឃើញវត្ថុបុរាណមួយកេសស្នូកអណ្ដើក! គ្រូធំនិយាយពីរបស់នោះហ្មែន?»

ពុកនាងសារភាពក្ដួរៗ ព្រោះក្ដីតក់ស្លុត ហើយក៏ជាពាក្យសារភាពដែលនាំឱ្យខ្ញុំ និងភរិយាគាត់ត្រូវស្ងាត់មាត់ដូចគេចុក។ សភាពរបស់មីង គឺគាត់មិនដឹងរឿងដ៏ជ្រៅទេដឹង? ប៉ុន្តែប្រសិនបើឱបមាថា ប្ដី

គាត់ពិតជាមានលាក់លៀមវត្ថុបុរាណនោះ តើដំណើរដើមទងវាមានអ្វីភ្ជាប់គ្នាជាមួយនឹងរឿងកាប់ដើមចម្ការថ្មីៗនេះ នឹងករណីជំងឺក្អកគ្រាំក្នុងរបស់គាត់?

តាសច្វាដកដង្ហើមជាមួយភាពស្លូតបូតរបស់គាត់ដែលខ្ញុំស្គាល់។ គាត់ពោលបង្គាប់មួយៗ៖

«ប្អូនឯងយកសងគេវិញទៅ របស់មិនមែនទ្រព្យយើង យកមកទុកមិនបានសុខទេ!»

ពុកនាងបដិសេធ៖

«កាលណោះខ្ញុំយកមកជីកទុកត្រង់គល់ឈើហ្នឹងឯង ព្រោះមិនចង់ឱ្យរដ្ឋអំណាចគេរឹបអូសយក! ខ្ញុំគិតថាពេលស្រុកគេសេរី ខ្ញុំនឹងយកទៅដោះដូរចែកគ្នា តែក្រោយមកខ្ញុំជីករកយ៉ាងណា ក៏រកមិនដែលឃើញហឹបនោះសោះ! អាកែមធ្លាប់មកម្តងជាពីរដង វាខឹងណាស់ ថាខ្ញុំនិយាយមិនពិត! ថ្មីៗនេះ វាសរសេរសារមកគំរាមកូនស្រីខ្ញុំទៀត! ពូឯងមើលចុះ ផ្ទះខ្ញុំមានអី ចុងក្រោយកូនប្រុសខ្ញុំឈឺធ្ងន់ ខ្ញុំសម្រេចចិត្តគាស់រកម្តងទៀត យកសោហ៊ុយសង្គ្រោះកូន ក៏ប៉ុន្តែខ្ញុំនៅតែរកមិនឃើញ! ឥឡូវគេឱ្យកាប់ដើមហ្នឹងចោល ខ្ញុំមិនហ៊ានជួលគេ មិនហ៊ានធ្វើពិធីអ្វី ខ្លាចគេមកច្រើន ដឹងរឿងខ្ញុំ មានតែខំជីកខ្លួនឯង ក្រែងរកឃើញ! លុងជ្រៅប៉ុណ្ណឹងហើយ នៅតែរកអីមិនឃើញសូម្បីមួយកម្ទេច! មិនដឹងថា វារសាត់ទៅណា ឬមួយអ្នកណាគាស់ទៅបាត់ទេ! ហឹបនោះជារឿងស្ងាត់ខ្លាំងណាស់ សូម្បីតែប្រពន្ធកូនសុទ្ធតែមិនដឹងរឿង! ហេតុអីកម្មធ្លាក់មកលើកូនប្រុសខ្ញុំ? សុំគ្រូជួយឱ្យវាជាដូចដើម ខ្ញុំសន្យាមិនចង់បានអ្វីទាំងអស់!»

ខ្ញុំចំហមាត់នឹងរឿងអស់នេះ ព្រោះកប់យោបល់។ សម្តីតាសច្វាលាន់មកវិញក្រោមការទន្ទឹងរង់ចាំរបស់ពួកយើង៖

«ក្នុងហឹបនោះមានអ្វីខ្លះ?»

គ្រប់គ្នាងាកសម្លឹងគាត់។ ពុកណានីនបិទភ្នែករកនឹកផង និយាយប្រាប់ផង៖

«មានខោអាវខ្លះជាសូត្រ តែមានដាំត្បូង ដាំពេជ្រ និងបិទមាសសុទ្ធជាជួរ! មានស្នៀតសក់ ក្រវិល និងគ្រឿងតូចៗច្រើនទៀតភាគច្រើនជាមាសសុទ្ធ!»

តាសច្វាឮហើយ ក៏បញ្ជាឱ្យខ្ញុំទៅរកអាវសារបាប់ គ្រឿងភ្លួងក្រាស់ៗមានលាបទឹកមាសក្រហមទែងហើយបង្គាប់ឱ្យរកហឹបដែកលាបពណ៌ស្ពាន់មកមួយផងដែរ។

ពួកយើងមិនដឹងទៅរកហឹបនោះនៅឯណា ក៏ជិះឆ្វេលទៅរកនៅម៉ុំហាងគ្រឿងបុរាណផ្សារទួលទំពូងឱ្យបានដល់ដៃគាត់។

បានកាលណា មេឃងងឹតស្លុបយកតែមែនទែនតែម្តងហើយ។ គាត់ឱ្យដាក់ហឹបថ្មីនោះនៅមុខម្ចាស់ផ្ទះពីរនាក់ប្តីប្រពន្ធដោយបង្គាប់ថា៖

«យើងត្រូវបញ្ឆោតព្រាយនោះឱ្យស្លៀកពាក់រាំច្រៀង ដោយខោអាវអស់នេះ ចំណែកហឹបទទេរនេះត្រូវឧបកិច្ចថាពេញដោយមាសកែវកង! ពេលព្រាយរាំច្រៀងសប្បាយក្អាកក្អាយ យើងនឹងសែនបរព្រៃឱ្យទៅវង្វេងក្នុងព្រៃលែងត្រឡប់មកវិញបាន! ពេលចប់កម្មវិធី យកហឹបនេះទៅទម្លាក់ចោលក្នុងដីនិយាយថា យកទៅវិញចុះ មិនមែនរបស់ខ្ញុំ ហើយកាយកប់បំបាត់ ព្រមទាំងនាំគ្នាបំភ្លេចវាចោលជារៀងរហូតទៅ!»

ពុកណានីនងក់ក្បាលយល់ព្រមតាមដំបូន្មានតាសច្ចាទាំងអស់។ បន្ទាប់មក គ្រប់គ្នាក៏ធ្វើតាមពាក្យគាត់ប្រាប់ ដោយរៀបចំរកភ្លេងមកចាក់សើចអឹងកង ហើយយកអាវសារបាប់គ្រឿងលម្អទៅដាក់លើកន្ទេលដែលក្រាលសែនព្រេននៅត្រង់គល់ឈើដែលទើបនឹងត្រូវបានគាស់រំលើងសល់ដីអាចម៍បំណះថ្មីមិនទាន់ស្ងួតស្រួលបួល។

តាសច្ចាអង្គុយពែនសមាធិនៅក្បែរនោះរហូតដល់គ្រប់យ៉ាងបានដូចការរំពឹងទុក គាត់ក៏បើកភ្នែកមកវិញដោយបញ្ជាឱ្យតាអាចារ្យពីរនាក់នាំពុកណានីន ឱបហឹបនោះរួមជាមួយពពួកគ្រឿងតុបតែងខ្លួនដែលរកបានមកទាំងប៉ុន្មានទៅទម្លាក់ចោលក្នុងដីដែលរំលើងឈើចម្ពាម។

តាអាចារ្យបង្គាប់ឱ្យពុកណានីននិយាយថា «យកទៅវិញចុះ មិនមែនរបស់ខ្ញុំទេ!»

ពេលគាត់ថាបានគ្រប់បីដង គេក៏កាយអាចម៍បំណះដីកប់បំបាត់ទីនោះរហូតដល់រៀបស្មើដូចដើមវិញ។

មិនយូរប៉ុន្មាន គ្រួសាររបស់ណានីនបានរស់សុខសាន្តដូចអ្នកផង ដោយឪពុក និងបងប្រុសក៏បានជាសះស្បើយម្តងបន្តិចៗរហូតដល់គ្រប់គ្នាបានបំភ្លេចរឿងដើមឈើមែកបែកជាពីរ និងករណីហឹបបុរាណនោះចោល។

ពីរឆ្នាំក្រោយមក ដោយទំនាក់ទំនងខ្ញុំ និងណានីនកាន់តែប្រសើរជាលំដាប់ ម្តាយនាងក៏សម្រេចចិត្តអនុញ្ញាតឱ្យខ្ញុំនាំចាស់ទុំមករកពេលារៀបការជាគូគ្រងតែម្តង។

ក្រោយរៀបការបានប្រមាណជាមួយខែ ណានីនក៏ទៅលេងស្រុក ហើយរកបានបងម្នាក់ឈ្មោះបងសារ៉ាយ គាត់ជាស្ត្រីមេម៉ាយគ្មានកូន និងគ្មានមុខរបរផង គាត់យល់ព្រមមករស់នៅជួយជំនួសដៃជើងការងារផ្ទះជាមួយម្តាយក្មេកខ្ញុំ។